ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លេខ......០៤៦...... ន.សផក

ថ្ងៃសុក្រ ០៤ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ:</u>** អំពីរបាយការណ៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប

**<u>យោង:</u>**
- សេចក្តីជូនដំណឹងលេខ១២០ ជនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ស្តីពីការអនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ៦៥១ ជនស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ៦៥៣ ជនស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា របាយការណ៍សវនកម្មផ្ទៃក្នុងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ជារបាយការណ៍អនុវត្តតាមគំរូស្តង់ដារបាយការណ៍សវនកម្ម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឱ្យគ្រប់ក្រសួង-ស្ថាប័នអនុវត្តតាម ហើយរបាយការណ៍នេះក៏នឹងត្រូវផ្ញើជូន អាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

ឆ្លងតាមការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិកា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាបសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៣ មានចំណុចល្អមួយចំនួនដូចជា÷

- កិច្ចបញ្ជិកា ការរៀបចំរក្សាឯកសារគណនេយ្យ ឯកសាររណប និងការកត់ត្រាមានសណ្តាប់ធ្នាប់ល្អជាងឆ្នាំកន្លងមក។
- ការអនុវត្តតាមអនុសាសន៍ដែលប្រតិភូសវនកម្មផ្ទៃក្នុងបានផ្តល់ជូនសម្រាប់ការិយបរិច្ឆេទកន្លងមកបានល្អប្រសើរ។

ទន្ទឹមនឹងនោះដែរ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា÷

**១- ការការទូទាត់ប្រាក់បេសកកម្ម**

-ការទូទាត់ប្រាក់បេសកកម្មពុំបានភ្ជាប់របាយការណ៍លទ្ធផលសកកម្មភាពការងារ។

**២- ការអនុវត្តការងារសំណង់**

-ក្នុងឆ្នាំ២០២៣ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប បានចេញលិខិតអនុញ្ញាតសាងសង់បានចំនួន ២៤គម្រោង លិខិតបើកការដ្ឋានបានចំនួន ០៨គម្រោង លិខិតបិទការដ្ឋានបានចំនួន ០១គម្រោង មិនសមាមាត្រនឹងចំនួនចេញលិខិតអនុញ្ញាតសាងសង់។

**៣- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ**

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ពុំមានបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ ម៉ាស៊ីនមេ (server) និងឃ្លាំងដាក់ឯកសារ (ប្រភេទម្សៅ)។

**៤- ការអនុវត្តការងារលទ្ធកម្ម**

-នៅក្នុងនីតិវិធីការដេញថ្លៃតាមលទ្ធកម្ម មន្ទីរពុំបានចុះលេខរៀង និងថ្ងៃខែឆ្នាំ។

**៥- ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី**

-ពីឆ្នាំ២០១៣ ដល់បច្ចុប្បន្នមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខូចចំនួន **៧,២៣៣**បណ្ណ។

**ប្រតិភូសវនកម្មបានផ្តល់អនុសាសន៍កែលម្អដូចខាងក្រោម÷**

**១- មន្ទីរ** ត្រូវធ្វើរបាយការណ៍លទ្ធផលសកម្មភាពការងារឱ្យបានគ្រប់ចំនួនពីមុខសញ្ញាទទួល។

**២- មន្ទីរ** ត្រូវធ្វើការផ្សព្វផ្សាយណែនាំដល់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ លិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់សំណង់ និងលិខិតអនុញ្ញាតបិទការដ្ឋានក្រោយពេលបញ្ចប់ការសាងសង់សំណង់។

**៣- មន្ទីរ** ត្រូវបំពាក់ប្រព័ន្ធការពារអគ្គីភ័យក្នុងបន្ទប់ម៉ាស៊ីនមេ (server) និងឃ្លាំងទុកឯកសារ (ប្រភេទម្សៅ)ជាបន្ទាន់។

**៤- មន្ទីរ** ត្រូវបំពេញលេខរៀង និងថ្ងៃខែឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួនតាមនីតិវិធីការងារលទ្ធកម្ម ស្របតាមសារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

**៥-មន្ទីរ** ត្រូវបង្កើតគណកម្មការដើម្បីត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុបដើម្បីដុតកម្ទេច យោងលើលិខិតលេខ ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

យួន_សុជាតិ

**បានឃើញ និងឯកភាព**

សូមគោរពជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប

ជារបាយការណ៍ និងមានមតិដឹកនាំ។

**ប្រធានក្រុមការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង**

ច័យន ឆ្វី